# ព្រះរាជសុន្ទរកថា

# ព្រះករុណាព្រះចៅអធិរាជ នៃប្រទេសជប៉ុន

នៅទីក្រុងតូក្យូ

ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១០

ខ្ញុំសូមសម្តែងនូវការស្វាគមន៍អស់ពីដួងហឫទ័យ ចំពោះព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ដែលបាន យាងមកបំពេញព្រះរាជដំណើរទស្សនកិច្ចជាផ្លូវរដ្ឋនៅប្រទេសជប៉ុន ។ ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ចំពោះព្រះរាជវត្តមានរបស់ព្រះករុណាព្រះមហាក្សត្រ នារាត្រីនេះ ។

ទំនាក់ទំនងរវាងប្រទេសកម្ពុជា និងប្រទេសជប៉ុនបានចាប់ផ្តើមឡើងនៅឆ្នាំ ១៥៦៩ ពេលដែលនាវាពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា បានមកដល់ឆ្នេរសមុទ្រ ក្យូហ្សូ ដើម្បីស្នើសុំចាប់ផ្តើមទំនាក់ទំនងពាណិជ្ជកម្ម ។ នៅពេលនោះ ប្រទេសជប៉ុនកំពុងស្ថិតក្នុងរយៈពេលអន្តរកាល ពីសម័យដែលមេទ័ពធំៗប្រជែងអំណាចគ្នា ទៅជាសម័យកាលនៃការបង្កើតនូវរដ្ឋាភិបាលមួយ ដែលសំរេចបាននូវការឯកភាពជាតិ ហើយពាណិជ្ជកម្មក្រៅប្រទេសក៏កំពុងតែកើនឡើងយ៉ាងសកម្មផងដែរ ។ ពីឆ្នាំ ១៦០៤ រហូតដល់ ១៦៣៥ ជាឆ្នាំ ដែលជនជាតិជប៉ុនបានត្រូវហាមឃាត់មិនអោយធ្វើដំណើរចាកចេញទៅក្រៅប្រទេស ដោយសារនយោបាយឯការនិយម ចំនួននាវាពាណិជ្ជកម្មជប៉ុន ដែលរដ្ឋាភិបាលបានផ្តល់លិខិតអនុញ្ញាតិអោយធ្វើនាវាចរណ៍ទៅប្រទេសកម្ពុជា គឺមាន ៤៤ គ្រឿង ។ ក្នុងចំណោមទំនិញនាំចូលមកពីប្រទេសកម្ពុជា មានស្បែកត្រីឆ្លាមដែលមានគុណភាពខ្ពស់ ហើយត្រូវបានគេប្រើប្រាស់សំរាប់រុំស្រោបដងដាវ និងធ្វើជាស្រោមដាវ ។ មុននឹងមានការផលិតឱសថ Promin សំរាប់ព្យាបាលជម្ងឺឃ្លង់ ប្រទេសជប៉ុនធ្លាប់បាននាំចូលរុក្ខជាតិម្យ៉ាងពីប្រទេសកម្ពុជា ហៅជាភាសាអង់គ្លេសថា Chaulmoogra សំរាប់យកមកផ្សំធ្វើជាឱសថព្យាបាលរោគឃ្លង់នេះអស់រយៈពេលដ៏យូរឆ្នាំ ។ នៅប្រទេសកម្ពុជាជំនាន់នោះ មានបុរីជនជាតិជប៉ុនចំនួនពីរកន្លែង ហើយអក្សរដែលសរសេរនឹងទឹក



ខ្មៅលើជញ្ជាំងប្រាសាទអង្គរវត្តដោយជនជាតិជប៉ុន ដែលបានទៅទស្សនាប្រាសាទនាពេលនោះ ក៏នៅមានសេសសល់នៅឡើយរហូតមកទល់ពេលបច្ចុប្បន្ន ។

ប៉ុន្តែ ដោយសារប្រទេសជប៉ុនបានបន្តនយោបាយឯការនិយមរយៈពេលជាង ២០០ ឆ្នាំ ទំនាក់ទំនងជាមួយប្រទេសកម្ពុជាក៏លែងមានតទៅទៀត ។ ម្យ៉ាងវិញទៀត នៅពេលដែលប្រទេសជប៉ុនបានផ្លាស់ប្តូរពីរបបនយោបាយឯការនិយម ទៅជានយោបាយបើកចំហប្រទេសនៅជាងពាក់កណ្តាលសតវត្សទី ១៩ ប្រទេសកម្ពុជាក៏បានស្ថិតនៅក្រោមការត្រួតត្រារបស់ប្រទេសបារាំង ។ ទំនាក់ទំនងរវាងប្រទេសយើងទាំងពីរបានចាប់ផ្តើមជាផ្លូវការនៅក្រោយសង្គ្រាមលោកលើកទី ២ គឺខណៈដែលប្រទេសយើងទាំងពីរទទួលបាននូវឯករាជ្យឡើងវិញរៀងៗខ្លួននៅក្នុងពេលវេលាប្រហាក់ប្រហែលគ្នា ។

ខ្ញុំបានជួបព្រះរាជបិតារបស់ព្រះអង្គ គឺព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យបូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ជាលើកដំបូងនៅក្រោយពេលដែលប្រទេសកម្ពុជាទទួលបានឯករាជ្យជាតិភ្លាម ដោយសារព្រះរាជបូជនីយកិច្ចរបស់ព្រះអង្គ ។ ព្រះករុណាព្រះមហាវីរក្សត្របានយាងមកបំពេញព្រះរាជដំណើរទស្សនកិច្ចជាផ្លូវរដ្ឋនៅប្រទេសជប៉ុន ហើយបានឡាយព្រះហស្តលេខាលើសន្ធិសញ្ញាចងស្ពានមេត្រីជាមួយរដ្ឋមន្ត្រីការបរទេសជប៉ុន ស៊ីង៉េមីហ្ស៊ូ (Shigemitsu) ។ ខ្ញុំក៏បានចូលរួមក្នុងព្រះរាជពិធីជប់លៀងពេលថ្ងៃត្រង់ រៀបចំដោយព្រះករុណាព្រះចៅអធិរាជ ហ្សូវ៉ា (Showa) និងព្រះអធិរាជនី កូជូន (Kojun) នៅក្នុងព្រះបរមរាជវាំង ។ ចាប់ពីពេលនោះមក រយៈពេល ៥៥ ឆ្នាំក៏បានកន្លងផុតទៅហើយដែរ ។ ខ្ញុំមានសេចក្តីសប្បាយរីករាយណាស់ ដោយបានដឹងថា ព្រះករុណាព្រះមហាវីរក្សត្រនៅមានព្រះរាជសុខភាពល្អបរិបូណ៌ ។

បន្ទាប់មកទៀត មាគ៌ាដែលប្រទេសកម្ពុជាបានឆ្លងកាត់នាពេលកន្លងទៅនេះពិតជាមានភាពលំបាកលំបិនជាទីបំផុត ។ ខ្ញុំមានសេចក្តីខ្លោចផ្សាក្នុងហឫទ័យយ៉ាងក្រៃលែងចំពោះការបាត់បង់អាយុជីវិតរបស់ប្រជាជនយ៉ាងច្រើនគួរអោយរន្ធត់ហឫទ័យ ដោយសារតែសង្គ្រាមស៊ីវិល។ ទុក្ខលំបាកដែលបានបន្សល់ទុកដោយសារសង្គ្រាមស៊ីវិលនេះបន្តមាននៅឡើយ ហើយខ្ញុំយល់ឃើញថា ចំនួនជនរងគ្រោះដោយសារគ្រាប់មីនដែលកប់ក្នុងដីនៅពេលនោះ ក៏មានមិនតិចឡើយ ។ ខ្ញុំគិតដល់កិច្ចខិតខំរបស់អ្នកដែលកំពុងធ្វើការបោសសំអាតគ្រាប់មីន ដែលបណ្តាលអោយមានការព្រួយបារម្ភចំពោះជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន ជាពិសេស គឺ កសិករ ហើយសង្ឃឹមថាការងារបោសសំអាតគ្រាប់មីននឹងប្រព្រឹត្តិទៅដោយសុវត្ថិភាព ។

ខ្ញុំបានជួបព្រះករុណាព្រះមហាក្សត្រជាលើកដំបូងនៅឆ្នាំ ១៩៨៨ ពេលដែលព្រះអង្គយាងមកប្រទេសជប៉ុនជាមួយព្រះករុណាព្រះរាជបិតា និងព្រះរាជមាតា ។ ពេលនោះ គឺជាពេលដែលប្រទេសកម្ពុជាបានឈានពីសង្គ្រាមស៊ីវិល ទៅជាការស្វែងរកសន្តិភាព ។ ព្រះករុណាបានគង់នៅជាមួយព្រះរាជបិតា និងព្រះរាជមាតានៅក្រោមសភាពការណ៍ដ៏តឹងតែងក្នុងរយៈពេលរហូតដល់សំរេចបានសន្តិភាព ។ ខ្ញុំគិតថា ព្រះករុណាប្រាកដជាមានទុក្ខលំបាកយ៉ាងអនេកដែលហួសពីការប៉ាន់ស្មានរបស់ខ្ញុំ ។

ប្រទេសកម្ពុជា បានពុះពារឆ្លងកាត់សង្គ្រាមស៊ីវិលដ៏ខ្លោចផ្សា ដោយសំរេចបាននូវសុខសន្តិភាព ហើយអនុវត្តការបោះឆ្នោតជាសាកល ធានាបាននូវស្ថិរភាពនយោបាយ និងកំពុងតែខិតខំប្រឹងប្រែងនាពេលបច្ចុប្បន្ននេះ ដើម្បីអភិវឌ្ឍថែមទៀត ។ ខ្ញុំសូមសម្តែងនូវគារវកិច្ចដ៏ស្មោះអស់ពីដួងហឫទ័យ ចំពោះកិច្ចខិតខំប្រឹងប្រែងឥតឈប់ឈររបស់ប្រជាជនកម្ពុជា ។



ប្រជាជនជប៉ុនបាន និងកំពុងធ្វើសហប្រតិបត្តិការជាមួយប្រជាជនកម្ពុជា ក្នុងការកសាងប្រទេសកម្ពុជាឡើងវិញ និងអភិវឌ្ឍក្នុងវិស័យផ្សេងៗ ។ ខ្ញុំសង្ឃឹមថា ព្រះរាជដំណើរទស្សនកិច្ចរបស់ព្រះករុណាព្រះមហាក្សត្រលើកនេះ នឹងក្លាយជាឱកាសមួយក្នុងការលើកទឹកចិត្តដល់ប្រជាជនដែលបានរួមវិភាគទាន នៅក្នុងកិច្ចសហប្រតិបត្តិការរវាងប្រទេសយើងទាំងពីរដូចខាងលើ ហើយនឹងពង្រឹងបន្ថែមនូវចំណងមិត្តភាពរវាងប្រជាជនយើងទាំងពីរ ក៏ដូចជាការលើកតម្កើងថែមទៀតនូវចំណាប់អារម្មណ៍ក្នុងចំណោមប្រជាជនជប៉ុនអំពីវប្បធម៌លំដាប់ថ្នាក់ពិភពលោកដ៏ល្អផូរផង់ ដែលជាទីមោទនភាពរបស់ប្រទេសកម្ពុជា ដូចជាប្រាសាទអង្គរវត្តជាដើម ។

នៅប្រទេសជប៉ុននាពេលនេះ គឺស្ថិតក្នុងរដូវដែលស្លឹកឈើទាំងឡាយកំពុងលូតលាស់មានពណ៌បៃតងយ៉ាងស្រស់ស្អាតពីមួយថ្ងៃ ទៅមួយថ្ងៃ ។ ខ្ញុំសង្ឃឹមថា ព្រះរាជដំណើរទស្សនកិច្ចរបស់ព្រះករុណានៅក្នុងប្រទេសជប៉ុន នាពេលដ៏ល្អត្រកាលនេះនឹងប្រកបដោយផ្លែផ្កា ។

ខ្ញុំសូមលើកកែវភេសជ្ជៈឡើង ដើម្បីព្រះរាជសុខភាពល្អបរិបូណ៌ថ្វាយព្រះករុណាព្រះមហាក្សត្រ និងដើម្បីសិរីសួស្តី និងសុភមង្គលរបស់ប្រជាជនកម្ពុជា ។